Remove Watermark Now

សង្ខារនុពលវប្បធម៌និងប្រវត្តិសាស្ត្រ នៅជួរភ្នំគុក ភូមិក្បាលដំរី ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់

ដោយ៖ ផុន កសិកា, ហឿង សុជារស់ និង តាកេត ស័កជា

នៅថ្ងៃសៅរ៍ ២រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានដឹកនាំក្រុមការងារជំនាញប្រវត្តិសាស្ត្រ និង បុរាណវត្ថុវិទ្យា ដែលមានលោកបណ្ឌិត ផុន កសិកា ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, លោក ហឿង សុជារស់ ប្រធានផ្នែកបុរាណវិទ្យានៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ និងកញ្ញា តាកេត ស័កជា មន្ត្រីស្ម័គ្រចិត្តនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ចុះសិក្សាស្រាវជ្រាវវាយតម្លៃពីសក្តានុពលស្ថានីយបុរាណវិទ្យា និងប្រវត្តិសាស្ត្រ (និយាមការ៖ x: 48P 0426143, Y: 1370116) ស្ថិតក្នុងភូមិក្បាលដំរី ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។

ស្ថានភាពភូមិសាស្ត្រនៃតំបន់នោះគឺជាទីតាំងភ្នំដែលមានព្រៃប្រឹក្សា ដើមឈើដុះច្រើន ព្រមទាំងមានថ្មធម្មជាតិផុសអណ្តែតពីដីដែលជាប្រភេទសិលាបន្ទុះភ្នំភ្លើង ឬសិលាម៉ាក់ម៉ា ដែលកើតចេញពីបន្ទុះភ្នំភ្លើងបណ្តាលពីការកកកឹងនៃម៉ាក់ម៉ានៅពេលចុះត្រជាក់។ ក្រៅពីសិលាម៉ាក់ម៉ា យើងសង្កេតឃើញមានសិលាកម្ទេចកំណៃដែលជាប្រភេទកើតឡើងពីការចាក់បង្គរជាស្រទាប់នៃកម្ទេចកំណៃ ឬកម្ទេចចាក់បង្គរដោយសារការជីកជញ្ជូនរបស់ទឹក និងខ្យល់។ នៅទីនោះក៏មានសិលាបាសាល់ដែរ។ នៅប្រទេសកម្ពុជាសិលាបាសាល់មានច្រើននៅតំបន់ខ្ពង់រាបខេត្តកំពង់ចាម។ ប្រភេទសិលាបាសាល់ច្រើនមានវាយនភាពប្រហោង ឬមានរន្ធច្រើន។ កាលពីសម័យហ្វូណនក្នុងរចនាបថភ្នំដា ខ្មែរបុរាណក៏បានយកថ្មបាសាល់មកសង់ជាប្រាសាទ ដូចនៅប្រាសាទអាស្រមមហាឫស្សីនៅខេត្តតាកែវ និងប្រាសាទហាន់ជ័យនៅខេត្តកំពង់ចាម។ យើងសង្កេតឃើញថា សិលាដែលមាននៅទីនោះ មានរូបរាងប្លែកៗពីគ្នា មានជាលក្ខណៈផ្ទាំងតូចឬធំ។ ផ្ទាំងធំៗមើលទៅដូចជារូបរាងអ្វីមួយដែលអាចធ្វើឱ្យគេច្រឡំថាជាស្នាដៃមនុស្សកែឆ្នៃសិលានេះបន្តែម។ ប៉ុន្តែ រូបរាងទាំងអស់គឺជាធម្មជាតិរបស់ថ្មដែលកាលពីដំណើរនៃការផ្ទុះភ្នំភ្លើង ម៉ាក់ម៉ាបានហៀរចេញពីស្រទាប់ផែនដី និងចុះត្រជាក់តាមទីតាំងផ្សេងៗ ហើយក៏ចេញជារូបរាងផ្សេងៗគ្នាបែបនេះ។

ប៉ុន្តែ នៅទីតាំងមួយ មានផ្ទាំងថ្មជាប្រភេទសិលាប្រែកំណើត (មិនស្គាល់ឈ្មោះពិតប្រាកដ) មានស្នាមដាប់យកថ្ម ហាក់ដូចជាទីយកថ្មសម័យបុរាណ។ បើទីនេះជាស្ថានីយយកថ្មមែន នេះបង្ហាញថាជាទីតាំងមានមនុស្សមករស់នៅក្នុងសម័យកាលណាមួយ។

Remove Watermark Now

នៅមានបដិមាព្រះពុទ្ធឆ្លាក់លើផ្ទាំងថ្មធម្មជាតិមានប្រវែង ៦,៦០ម៉ែត្រ និងប្រវែងដងខ្លួនព្រះពុទ្ធ ២,៥០ម៉ែត្រ ព្រះសិរបែរទៅទិសខាងកើត ដៃលព្រះសិរទ្រដោយព្រះហស្តខាងឆ្វង។ ចម្លាក់ព្រះពុទ្ធបដិមាស្លៀកសំពត់ តែមិនគ្រងស្បង់ជីពរទេ។ ចំណែក ក្នងសក់គេរចនាកេសាដោយបួងពីរជាន់។ នៅជិតព្រះបាទមានស្នាមរន្ធសរសេរសម្រាប់ដាក់សរសរសង់រោងប្រក់ពីលើការពារចម្លាក់ព្រះពុទ្ធ និងសម្រាប់ជាទីម្លប់ដល់ពុទ្ធសាសនិកដៃលមកគោរពបូជាផងដៃរ។ ជាការសិន្និដ្ឋានបណ្តោះអាសន្ន ចម្លាក់ព្រះពុទ្ធនេះប្រហៃលកសាងនៅសម័យក្រោយ ប៉ុន្តៃក្រុមការងារក៏មិនអាចវាយតម្លៃពេលវេលាពិតប្រាកដពេលណាដៃលរូបព្រះពុទ្ធត្រូវបានគេឆ្លាក់នោះទេ។

នៅពីមុខចម្លាក់ព្រះពុទ្ធ មានផ្ទាំងសិលាឆ្លាក់គំនូររូបមនុស្សក្នុងកាយវិការអោន ឈ្ងោកមើលអ្វីមួយ និងគំនូររូបសត្វដំរី មានមនុស្សជិះពីលើ។ យ៉ាងណា ទឹកដៃ និងសម្រស់នៃគំនូរ ហាក់មិនមានមាត្រដ្ឋានជាក់លាក់។ តាមការសង្កេត ស្នាមគំនូរទាំងពីរនេះ ក្រុមការងារមិនអាចសន្និដ្ឋានថាជាស្នាមចម្លាក់សម័យបុរាណ ឬ គេគូសនៅសម័យក្រោយៗថ្មីៗទេ។

ភស្តុតាងចុងក្រោយផ្សេងទៀតដៃលយើងបានឃើញមាននៅស្ថានីយគឺកុលាលភាជន៍ចំនួន២។ កុលាលភាជន៍ទាំងពីរមានរូបរាងជាថូ ធ្វើពីដីដុត ជាប្រភេទកុលាលភាជន៍រឹង (stoneware) មានស្រទាប់រលោង។ តាមការវិភាគជាបឋម កុលាលភាជន៍ទាំងពីរផលិតនៅសម័យអង្គរ ក្នុងសម័យកាលយ៉ាងហោចណាស់ចាប់ពីសតវត្សទី១២-១៣។

ជាសន្និដ្ឋាន ស្ថានីយនេះមានសក្តានុពលធនធានធម្មជាតិមានដូចជាព្រៃឈើ សត្វព្រៃ ផ្ទាំងសិលាដៃលមានរូបរាងប្លែកៗ និងធនធានវប្បធម៌ដៃលមានរូបចម្លាក់ព្រះពុទ្ធ គំនូរលើផ្ទាងថ្ម និងកុលាលភាជន៍នាសម័យអង្គរ។

pdfelement

Remove Watermark Now



ផែនទីស្ថានីយជួរភ្នំគុក ក្នុងឃុំអន្សាចំបក់

pdfelement

Remove Watermark Now

សិលាដែលសង្ឃឹយថាមានមនុស្សយកថ្មនៅសម័យបុរាណ

សិលាម៉ាក់ម៉ា

Remove Watermark Now

សិលាម៉ាក់ម៉ា ដែលជាក្រុមសិលាបាសាល់



សិលាប្រៃកំណើត

Remove Watermark Now



សិលាបន្ទុះភ្នំភ្លើង

ចម្លាក់ព្រះពុទ្ធ

Remove Watermark Now



គំនូររូបមនុស្ស និង សត្វជំរីមនុស្សជិះពីលើធ្លាក់លើផ្ទាំងថ្ម

កុលាលភាជន៍ជាប្រភេទកុលាលភាជន៍រឹង

pdfelement

Remove Watermark Now

ក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

pdfelement

ក្រុមការងារស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជាវាស់ប្រវែងបដិមាព្រះពុទ្ធ

Remove Watermark Now

ក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជា មន្ទីរវប្បធម៌ខេត្តពោធិ៍សាត់ និងព្រះសង្ឃ

ក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជា និងអាជ្ញាធរឃុំ

Remove Watermark Now

ក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជា មន្ទីរវប្បធម៌ខេត្តពោធិ៍សាត់

ក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជា មន្ទីរវប្បធម៌ខេត្តពោធិ៍សាត់